**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង ខេត្តសៀមរាប**
**សាលក្រម លេខ ១៤ "ខ.១"/៥១១**
ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១
- សំណុំរឿងព្រហ្មទណ្ឌលេខ ១៨១
ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥
- សំណុំរឿងជំនុំជម្រះលេខ ៦០៨
ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូង ខេត្តសៀមរាប

កាលបរិច្ឆេទនៃសវនាការជាសាធារណៈ ៖ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១
សាលសវនាការ និងពេលវេលា ៖ សាល លេខ ក២ ព្រឹក
កាលបរិច្ឆេទនៃការប្រកាសសាលក្រម ៖ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១
សាលសវនាការ និងពេលវេលា ៖ សាលលេខ ក២ ព្រឹក

### ក្រុមប្រឹក្សាជំនុំជម្រះ

១-លោក [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប ជាប្រធានក្រុមប្រឹក្សា
២-លោក [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប ជាចៅក្រមប្រឹក្សា
៣-លោក [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូង ខេត្តសៀមរាប

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូង ខេត្តសៀមរាប

ដើម្បីជំនុំជម្រះ និងប្រកាសសាលក្រម លើពាក្យបណ្តឹងទាស់ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] **បារាំង** ជនជាប់ចោទ ចំពោះសាលក្រមព្រហ្មទណ្ឌ លេខ ៦០ "ជ" ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ ១៨១ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥ ដែលមាន៖

- ជនជាប់ចោទឈ្មោះ [redacted] បារាំង ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនា ព្រះពុទ្ធ មានទីកន្លែងកំណើតនៅ ភូមិព្រៃកស្រមោច ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប មានទីលំនៅបច្ចុប្បន្ន [redacted] ស្រុកសូទ្រនិគម ខេត្តសៀមរាប មុខ



Scanned with CamScanner

របរ ជាងដែក កម្រិតវប្បធម៌ថ្នាក់ទី ០៦ ប្រពន្ធឈ្មោះ[redacted](រស់) គ្មានកូន ឪពុកឈ្មោះ[redacted] (រស់) ម្ដាយឈ្មោះ[redacted](រស់) ទោសពីមុន គ្មាន។

ដីកាបង្គាប់ឲ្យឃុំខ្លួនពិរុទ្ធជន លេខ ១៧៦/២០២១ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ ២០២១។

មានលោក[redacted]វីរៈ ជាមេធាវីការពារសិទ្ធិ។

**ត្រូវជាប់ចោទពីបទ** "រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ" ប្រព្រឹត្តនៅ ភូមិព្រែកស្រមោច ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៥ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ ចំនុចទី១ នៃក្រមព្រហ្មទណ្ឌ។

## ដើមបណ្ដឹងរដ្ឋប្បវេណី

ឈ្មោះ[redacted]សុជាតិ ភេទប្រុស សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅ ភូមិព្រែកស្រមោច ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប។

## ជនរងគ្រោះ

ឈ្មោះ[redacted]ស្រីអូន ភេទស្រី អាយុ១៤ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅ[redacted] ស្រុកសូទ្រនិគម ខេត្តសៀមរាប។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៩៤៥ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូង ខេត្តសៀមរាប។

- បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ លេខ ៣៨០៤ ចុះ ថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូង ខេត្តសៀមរាប។

- បានឃើញ ដីកាផ្តល់ដំណឹងកាលបរិច្ឆេទសវនាការ ដែលធ្វើឡើងដោយមានអនុលោមតាមមាត្រា ២៩២ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌ លេខ ៦០ "ខ" ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តសៀមរាប ដែលបានសម្រេចសេចក្តី៖

**១-ផ្តន្ទាទោសជនជាប់ចោទ៖**

-ឈ្មោះ[redacted] បារាំង ភេទប្រុស អាយុ២១ឆ្នាំ (សាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ៥ (**ប្រាំ**) **ឆ្នាំ គិតពីថ្ងៃ ចាប់ខ្លួនបាន។**

**ពីបទ** "រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ" ប្រព្រឹត្តនៅ ភូមិព្រែកស្រមោច ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៥ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ ចំនុចទី១ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

**២- ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនលើជនជាប់ចោទ** ឈ[redacted]បារាំង (ដែលមានសាវតារជាតិដូចខាងលើ) តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**៣-** សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ ពាក្យបណ្តឹងទាស់ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១ របស់ជនជាប់ចោទ ឈ្មោះ[redacted] **បារាំង** ចំពោះសាលក្រមព្រហ្មទណ្ឌ លេខ ៦០ "ខ" ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥។

## អង្គហេតុដែលប្តឹងមកតុលាការ

កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៥ ស្ថិតនៅ ភូមិព្រៃកស្រមោច ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប ឈ្មោះ[redacted] ស្រីអូន ភេទស្រី អាយុ០៩ឆ្នាំ បានដើរទៅបត់ជើងធំជាមួយឈ្មោះ យ៉ុង និងឈ្មោះ ហុង ក៏បានជួបជាមួយឈ្មោ[redacted]បារាំង ភេទប្រុស អាយុ២១ឆ្នាំ កំពុងដើរបាញ់សត្វ ហើយឈ្មោ[redacted]បារាំង បានបបួលឈ្មោះ [redacted] ស្រីអូន ទៅក្បែរស្រះចិញ្ចឹមត្រី។ ពេលទៅដល់ឈ្មោះ [redacted] បារាំង បានចាប់ស្រាតខោ និងឲ្យឈ្មោះ [redacted] ស្រីអូន ដេកទៅលើដី និងបានយក[redacted] ស្រីអូន រួចក៏ឲ្យឈ្មោះ [redacted] ស្រីអូន[redacted]ភេទរបស់ខ្លួនទៀត។ លុះក្រោយមកប្រព្រឹត្តរួច ឈ្មោះ [redacted] បារាំង បានឲ្យប្រាក់ទៅឈ្មោ[redacted]ស្រីអូន ចំនួន មួយពាន់រៀល។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ[redacted] បារាំង បានឆ្លើយថា៖ ខ្លួនមិនបានប្រព្រឹត្តអំពើដូចការចោទប្រកាន់ទេ។ នៅថ្ងៃកើតហេតុនោះ ខ្លួននៅផ្ទះមិនបានជួបជាមួយឈ្មោះ[redacted] ស្រីអូន នោះទេ។ ឪពុករបស់ឈ្មោះ [redacted]ស្រីអូន ត្រូវជាឪពុកមារខ្លួន ប៉ុន្តែខ្លួនមិនដែលនិយាយរកគ្រួសារឈ្មោះ [redacted]ស្រីអូន ទេ ព្រោះគ្រួសារខ្លួន និងគ្រួសារឈ្មោ[redacted]ស្រីអូន ធ្លាប់មានទំនាស់ជាមួយគ្នា ប៉ុន្តែមិនដឹងមានទំនាស់រឿងអ្វីទេ ឪពុកខ្លួនទើបដឹង។ កាលពីឆ្នាំ២០១៥ ខ្លួននៅស្រុកសូទ្រនិគម ធ្វើស្រែ ខ្លួនមិនបានទទួលដីកាកោះរបស់តុលាការដោយផ្ទាល់ទេ ប៉ុន្តែឪពុកខ្លួនបានទទួល និងប្រាប់ខ្លួន ប៉ុន្តែខ្លួនមិនបានចូលខ្លួនទៅតុលាការ ដោយសារខ្លួនរវល់ធ្វើការ។ ខ្លួនមិ[redacted] ស្រីអូន និងមិនបានឲ្យលុយទៅឈ្មោះ ស្រីអូន មួយពាន់រៀល នោះទេ។ ខ្លួនក៏ធ្លាប់ទៅធ្វើការនៅថៃដែរ។ ឪពុកខ្លួនបានសងសំណងទៅឲ្យឪពុកឈ្មោះ ស្រីអូន ចំនួន មួយលានរៀល ដើម្បីកុំឲ្យឪពុកឈ្មោះ ស្រីអូន ប្តឹង និងសុំបញ្ចប់រឿង។



Scanned with CamScanner

- ជនរងគ្រោះឈ្មោះ[redacted]ស្រីអូន បានឆ្លើយថា៖ ឈ្មោះ បារាំង បានរំលោភខ្លួន ចំនួន ពីរលើក នៅក្នុងថ្ងៃតែមួយ ដោយនៅថ្ងៃកើតហេតុនោះ ឈ្មោះ បារាំង បានយក[redacted]ខ្លួន ប្រហែលជា ពីរនាទី មាន[redacted] និងបាន[redacted]និងគម្រាមខ្លួនទៀត។ មុនពេលឈ្មោះ បារាំង រំលោភខ្លួន គឺខ្លួន ឈ្មោះ គុណ និងឈ្មោះ ចន្ទ នាំគ្នាទៅកាប់អុស។ ឈ្មោះ គុណ ឃើញឈ្មោះ បារាំង ចាប់ខ្លួននៅជុំបខ្វាង ជិតស្រះត្រី និងឃើញ[redacted]បារាំង ដែរ ឈ្មោះ គុណ ចង់មកជួយដែរ តែជួយអត់បាន ហើយឈ្មោះ បារាំង បានឲ្យលុយខ្លួន មួយពាន់រៀល ប៉ុន្តែខ្លួនបោះចោល ខ្លួនអត់យក។ ពីមុនខ្លួនមិនដែលលេងជាមួយឈ្មោះ បារាំង ទេ ខ្លួនខ្លាចគាត់។ រំលោភលើកទីពីរនៅថ្ងៃដដែល [redacted]បារាំង ពីរដង។

- សាក្សីឈ្មោះ[redacted]សុជាតិ បានឆ្លើយថា៖ ខ្លួនបានដកពាក្យបណ្ដឹងដោយសារ គ្រួសារឈ្មោះ បារាំង បានអង្វរខ្លួនពេក ខ្លួនអាណិត និងស្រណោះ ទើបខ្លួនឈប់ប្ដឹង ហើយដកពាក្យ និងមិនទាមទារសំណងអ្វីទេ។ ខ្លួនធ្លាប់ទទួលបានលុយខ្លះពីគ្រួសារឈ្មោះ បារាំង មែន ប៉ុន្តែមិនដល់ មួយលានរៀលទេ។ ខ្លួនមិនបាននៅកន្លែងកើតហេតុទេ គ្រាន់តែលឺកូនប្រាប់ នៅថ្ងៃកើតហេតុពួកវា មានគ្នាបីនាក់បងប្អូន។ ក្រោយកើតហេតុខ្លួន បាននាំកូនទៅពេទ្យពិនិត្យដែរ ពេទ្យប្រាប់ថា ប្រដាប់ភេទមានដាច់រលាត់ ប៉ុន្តែឯកសារពិនិត្យនោះនៅឯណា ខ្លួនមិនចាំទេ។ ខ្លួនធ្លាប់មានទំនាស់ជាមួយឪពុករបស់ឈ្មោះ បារាំង បន្តិចបន្តួចដែរ។

- សាក្សីឈ្មោះ[redacted]លាងគុណ បានឆ្លើយថា៖ ពេលនេះ ខ្លួនថ្លង់ស្ដាប់មិនសូវបានទេ ខ្លួនរក្សាចម្លើយពីមុនដដែល។ ឈ្មោះ[redacted]បារាំង ពិតជាបានចាប់សំរាតខោឈ្មោះ[redacted]ស្រីអូន ហើយអោយឈ្មោះ ជាតិ ស្រីអូន ដេកនៅលើដី រួចវាឡើងជិះពីលើ បានបន្តិចក៏ក្រោកវិញបន្ទាប់មកឃើញវាអោយបងស្រី[redacted]ទៀត បានបន្តិចក៏ឃើញឈ្មោះ បារាំង ហុចប្រាក់ឲ្យបងស្រីខ្លួនចំនួន មួយពាន់រៀល ខ្លួនឃើញបងស្រីខ្លួនហែកប្រាក់នោះចោល។ នៅដំណាក់កាលចៅក្រមស៊ើបសួរសាក្សីឈ្មោះ[redacted]លាងគុណ បានឆ្លើយថា ខ្លួនមិនបានឃើញឈ្មោះ បារាំង ចាប់រំលោភឈ្មោះ[redacted]ស្រីអូន នោះទេ កាលដែលខ្លួនឆ្លើយនៅប៉ូលីសនោះគឺចេះតែឆ្លើយទៅ។

- ឈ្មោះ[redacted]ចន្ទ ជាសាក្សីបានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ខ្លួនឃើញឈ្មោះ ស្រីអូន [redacted] ឈ្មោះ បារាំង និងយំស្រែកឲ្យខ្លួនជួយ ប៉ុន្តែខ្លួនជួយអត់បាន ខ្លួនខ្លាច និងឃើញឈ្មោះ បារាំង កាន់ដាវ រកដេញកាប់ពួកខ្លួន។ ខ្លួនឃើញឈ្មោះ បារាំង [redacted]និងឲ្យលុយស្រីអូន មួយពាន់រៀល តែស្រីអូន អត់ និងបោះចោល។ ពេលនោះ ពួកខ្លួនមានគ្នាបីនាក់ នាំគ្នាទៅកាប់អុស ហើយក៏ជួបឈ្មោះ បារាំង តាមផ្លូវ។ គ្រួសារខ្លួន មិនដែលនិយាយរកគ្រួសារឈ្មោះ បារាំង ទេ។



Scanned with CamScanner

49/4

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ទោះបីជាចម្លើយរបស់ជនរងគ្រោះ និងសាក្សីឆ្លើយមិនបានក្បោះក្បាយមែន ដោយសាររឿងកើតឡើងយូរហើយ ប៉ុន្តែអង្គហេតុមិនមានអ្វីកែប្រែនោះទេ គឺមានការ[redacted] និងឲ្យលុយ មួយពាន់រៀល ទៅជនរងគ្រោះ ដូច្នេះ តំណាងអយ្យការស្នើសុំតុលាការសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌ លេខ ៦០ "ជ" ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សាលាដំបូង ខេត្តសៀមរាប ទុកជាបានការដដែល។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

លោក[redacted]វីរៈ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោ[redacted] បារាំង បានធ្វើសេចក្តីសន្និដ្ឋានការពារថា ឆ្លងតាមការស្តាប់ចម្លើយ ឃើញថា ករណីនេះ ស្ថិតនៅក្នុងវិមតិសង្ស័យ ពាក់ព័ន្ធនឹងចម្លើយរបស់ជនរងគ្រោះ ក៏គាត់ឆ្លើយមិនច្បាស់លាស់ដែរ ហើយគ្រួសារពួកគាត់ធ្លាប់មានទំនាស់ជាមួយគ្នា ម្យ៉ាងសាក្សីថា គាត់បានរត់បាត់ ដូច្នេះ គាត់មិនអាចឃើញហេតុការទេ។ រឿងនេះ គ្មានកោសលវិច័យ ហើយបទល្មើសជាបទឧក្រិដ្ឋ ដើមចោទក៏បានដកពាក្យបណ្តឹងដែរ ដូច្នេះ ស្នើសុំតុលាការសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ និងដោះលែងគាត់ឲ្យមានសេរីភាពវិញ។

## សិទ្ធិនិយាយសំដីចុងក្រោយរបស់ជនជាប់ចោទ

ឈ្មោ[redacted]បារាំង ជាជនជាប់ចោទ ខ្លួនស្នើសុំតុលាការដោះលែងខ្លួន ឲ្យមានសេរីភាពវិញ។

- ក្រោយពី បានស្តាប់ចម្លើយរបស់ជនជាប់ចោទ ជនរងគ្រោះ និងសាក្សី
- ក្រោយពី បានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពី បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយពី បានពិភាក្សាពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

១- សាលាដំបូងខេត្តសៀមរាប បានទទួលពាក្យបណ្តឹងទាស់របស់ជនជាប់ចោទឈ្មោ[redacted]បារាំង លើសាលក្រមលេខ ៦០ "ជ" ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ ១៨១ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥ ដែលជនជាប់ចោទឈ្មោះ[redacted] បារាំង ភេទប្រុស អាយុ២៧ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) ត្រូវបានក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូង ខេត្តសៀមរាប សម្រេចផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ៥ (ប្រាំ) ឆ្នាំ គិតពីថ្ងៃ ចាប់ខ្លួនបាន ពីបទ "រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ" ប្រព្រឹត្តនៅ ភូមិព្រែកស្រមោច ឃុំកំពង់ឃ្លាំង ស្រុក



Scanned with CamScanner

សូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៥ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាម បញ្ញត្តិមាត្រា ២៤១ ចំនុចទី១ នៃក្រមព្រហ្មទណ្ឌ។

២- តាមមាត្រា ៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នាំឱ្យសាលាដំបូង ខេត្តសៀមរាប មានសមត្ថកិច្ចក្នុងការជំនុំជម្រះលើអង្គហេតុដែលប្តឹងមកតុលាការ និងចំពោះជនជាប់ចោទឈ្មោះ [redacted] បារាំង ភេទប្រុស អាយុ២៧ឆ្នាំ (ដូចមានអត្តសញ្ញាណខាងលើ)។

៣- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បារាំង បានឆ្លើយថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ខ្លួនមិនបាន [redacted]ស់ខ្លួនចូលទៅក្នុងប្រដាប់ភេទរបស់ជនរងគ្រោះ និងមិនបានឲ្យលុយទៅជនរងគ្រោះ មួយពាន់រៀល នោះទេ គប្បី តុលាការមិនអាចជឿបានឡើយ ព្រោះគ្រាន់តែជាចម្លើយដោះសារ ដើម្បីរួចផុតពីបទចោទប្រកាន់ប៉ុណ្ណោះ ព្រោះតាមចម្លើយជនរងគ្រោះ និងសាក្សីទាំងអស់ក្នុងពេលសវនាការ គឺមិនខុសគ្នាពីចម្លើយមុនៗនោះទេ គឺឈ្មោះ [redacted] បារាំង ពិតជា[redacted] ជនរងគ្រោះ [redacted] ដោយធ្វើឲ្យប្រដាប់ភេទរបស់ជនរងគ្រ[redacted] និងបានឲ្យជនរងគ្រោះ[redacted]បស់ខ្លួន ព្រមទាំងបានឲ្យលុយទៅជនរងគ្រោះ មួយពាន់រៀល និងគម្រាមជនរងគ្រោះ ផងដែរ ដែលអំពើរបស់ឈ្មោះ [redacted] បារាំង ជាបទ "រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ" ប្រព្រឹត្តនៅ ភូមិព្រែកស្រមោច ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៥ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ ចំនុចទី១ នៃក្រមព្រហ្មទណ្ឌ។

៤- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បារាំង ក៏បានឆ្លើយដែរថា គ្រួសារខ្លួនបានឲ្យប្រាក់ចំនួន មួយលានរៀល ទៅជនឪពុករបស់ជនរងគ្រោះ ដើម្បីកុំឲ្យប្តឹង និងសុំបញ្ចប់រឿង មានភាពស៊ីសង្វាក់គ្នាគ្រប់គ្រាន់នឹងចម្លើយរបស់ឈ្មោះ [redacted] សុជាតិ ដែលជាឪពុករបស់ជនរងគ្រោះ ដែលបានឆ្លើយថា ខ្លួនបានទទួលលុយខ្លះពីគ្រួសាររបស់ឈ្មោះ បារាំង ហើយគ្រួសារឈ្មោះ បារាំង អង្វរពេក ខ្លួនអាណិត ទើបដកពាក្យបណ្តឹង បង្ហាញឱ្យឃើញថា នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៥ នៅចំណុច ភូមិព្រែកស្រមោច ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប ពិតជាមានបទល្មើស "រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ" កើតឡើង ប្រព្រឹត្តដោយឈ្មោះ [redacted] បារាំង ដែលជាបទល្មើស ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ ចំនុចទី១ នៃក្រមព្រហ្មទណ្ឌ។

៥- តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] លាងគុណ បានឆ្លើយស្របគ្នាទៅនឹងចម្លើយរបស់សាក្សីឈ្មោះ [redacted] ចន្ធូ និងស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់ជនរងគ្រោះ គឺមានកា[redacted]

ដាប់ភេទជនរងគ្រោះ ព្រមទាំងជនជាប់ចោទបា[redacted] ពិតប្រាកដមែន។

៦- មានបន្ទុក និងភស្តុតាង គ្រប់គ្រាន់លើជនជាប់ជនឈ្មោ[redacted]បារាំង ភេទប្រុស អាយុ២៧ឆ្នាំ ពីបទ "រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ" ប្រព្រឹត្តនៅ ភូមិព្រៃកស្រមោច ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៥។

៧- មានភស្តុតាងស៊ីសង្វាក់គ្រប់គ្រាន់ក្នុងសំណុំរឿង បង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោ[redacted] បារាំង ពិតជាមានចេតនាក្នុងការបង្កឱ្យមានបទល្មើសកើតឡើង ដែលពិតជាបានប៉ះពាល់ដល់បូរណភាពរាងកាយ សេចក្តីថ្លៃថ្នូរ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសុវត្ថិភាពសង្គមដែលត្រូវជានាការពារដោយច្បាប់ជាធរមាន។ ម្យ៉ាងវិញទៀត ជនត្រូវចោទមានស្មារតីល្អ អាចយល់ដឹងនូវអំពើ និងបច្ច័យនៃអំពើរបស់ខ្លួន និងអាចទទួលខុសត្រូវនូវការប្រព្រឹត្តរបស់ខ្លួនបាន។

៨- តាមសាលក្រមលេខ ៦០ "ជ" ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សាលាដំបូង ខេត្តសៀមរាប បានសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោ[redacted] បារាំង ដាក់ពន្ធនាគារកំណត់ ៥ (ប្រាំ) ឆ្នាំ គិតពីថ្ងៃ ចាប់ខ្លួនបាន ពីបទ "រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ" និងមិនបានសម្រេចអំពីសំណងនោះទេ ដោយសារឈ្មោ[redacted]សុជាតិ ជាឪពុករបស់ជនរងគ្រោះ មិនបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការទាមទារសំណង និងបានដកពាក្យបណ្តឹង។

៩- ជនជាប់ចោទឈ្មោ[redacted]បារាំង ត្រូវបានចាប់ខ្លួនតាមអានុភាពនៃដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងខេត្តសៀមរាប និងត្រូវបានឃុំខ្លួន នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១ តាមដីកាបង្គាប់ឱ្យឃុំខ្លួនពិរុទ្ធជន លេខ ១៧៦/២០២១ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប។

១០- អង្គហេតុនៃបទល្មើសនេះ បានកើតនៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៥ ពេលដែលជនរងគ្រោះ និងបងប្អូននាំគ្នាទៅកាច់អុស ហើយជនជាប់ចោទក៏ឆ្លៀតឱកាសរំលោភលើជនរងគ្រោះ ដែលជាក្មេងមិនទាន់គ្រប់អាយុ គ្មានលទ្ធភាពតស៊ូបាន។ ឃើញថា ក្រោយពេលកើតហេតុមក រហូតសព្វថ្ងៃ ជនរងគ្រោះនៅតែមានបញ្ហាស្មារតី មានភាពភ័យខ្លាច ទោះបីជាបទល្មើសនោះ ត្រូវបានបញ្ចប់ហើយក៏ដោយ។ លើសពីនេះទៀត ក្រោយអង្គហេតុ ឈ្មោ[redacted]បារាំង មិនបានទទួលស្គាល់នូវកំហុសរបស់ខ្លួនបានប្រព្រឹត្តនោះទេ។ តាមមូលហេតុ កាលៈទេសៈ និងស្ថានភាពទាំងអស់នេះ តុលាការត្រូវពិនិត្យ ពិចារណា និងសម្រេចផ្តន្ទាទោសលើជនជាប់ចោទ ដដែល ដោយមិនផ្តល់នូវស្ថានសម្រាលទោស ឬអនុវត្តនូវបែបព្យួរទោសធម្មតាមួយផ្នែកណាមួយឡើយ។



Scanned with CamScanner

១១- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំឲ្យតុលាការ សម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌ លេខ ៦០ "ជ" ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សាលាដំបូង ខេត្តសៀមរាប ទុកជាបានការដដែល ឃើញថា ការប្តឹងសុំនេះ តុលាការពិនិត្យ ពិចារណា និងសម្រេច តាមភាពសមរម្យ តាមមូល ដ្ឋានច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

១២-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារ ស្នើសុំឲ្យតុលាការ សម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ និងដោះលែងកូនក្តីខ្លួនឲ្យមានសេរីភាព តុលាការ យល់ឃើញថា ការស្នើសុំនេះមិនត្រឹមត្រូវនោះទេ តុលាការមិនពិចារណា និងសម្រេច តាមការស្នើសុំនេះទេ។

**សាលាដំបូង ខេត្តសៀមរាប**

**វិនិច្ឆ័យសេចក្តី**

១- **ទទួលពាក្យបណ្តឹងទាស់** ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]**ធារ៉ាំង** (អត្តសញ្ញាណដូចខាងលើ)។

២- **តម្កល់សាលក្រមព្រហ្មទណ្ឌ** លេខ ៦០ "ជ" ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ ទុកជាបានការ **ដោយសម្រេចផ្តន្ទាទោសលើជនជាប់ចោទ** ឈ្មោះ [redacted]**ធារ៉ាំង** ភេទប្រុស អាយុ២៧ឆ្នាំ (អត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល **០៥ ឆ្នាំ**។

**ពីបទ** "រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ" ប្រព្រឹត្តនៅភូមិព្រៃកស្រមោច ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៥ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ ចំនុចទី១ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ និងជនរងគ្រោះ។

ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខ[redacted] | ហត្ថលេខ[redacted] | ហត្ថលេខា និងត្រា[redacted] |

**បានឃើញ**
ថ្ងៃពុធ ១៣រោច ខែបឋមសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
សៀមរាប, ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១
**ប្រធានក្រុមប្រឹក្សា**
[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃពុធ ១៣រោច ខែបឋមសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
សៀមរាប, ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១
**ក្រឡាបញ្ជី**
[redacted]



Scanned with CamScanner